00275165

E5/10

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 01 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C. Ary

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ |
| ភាគីបញ្ជូន៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម៖ | អង់គ្លេស |
| ប្រភេទឯកសារ៖ | សាធារណៈ |

---

## ញត្តិរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់បន្ថែមនូវភស្តុតាងថ្មីៗ

---

**បញ្ជូនដោយ៖**
**ការិ.សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក ពេជ្រ សម្បត្តិ
លោក Alex BATES

**បញ្ជូនទៅ៖**
**អង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សាខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

**ចម្លងជូន៖**
**ជនត្រូវចោទឈ្មោះ៖**
កាំង ហ្កេកអ៊ាវ ហៅ "ឌុច"

**មេធាវីរបស់ជនត្រូវចោទ៖**
លោក ការ សាវុត្ថ
លោក François ROUX

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**
លោក គង់ ពិសី
លោក ហុង គីមសួន
លោក យុង ផានិត
លោក គីម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
លោកស្រី Silke STUDZINSKY
លោកស្រី Martine JACQUIN
លោក Philippe CANNONE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 29 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

E5/10

*សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ*

## ១. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៣៩.៤ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញា សូមជូនយោបល់ និងស្នើដល់អង្គជំនុំជម្រះសាលាដំបូង សុំអនុញ្ញាតឱ្យសហព្រះរាជអាជ្ញា ដាក់បន្ថែមនូវបញ្ជីឯកសារ និងកញ្ចប់វត្ថុតាងថ្មីៗរបស់ខ្លួន ដែលបានដាក់កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ ដើម្បីដាក់បញ្ចូលភស្តុតាងថ្មីៗដែលទើបបានរកឃើញនៅក្រោយថ្ងៃដាក់ឯកសារទាំងអស់នោះ ។

## ២. ប្រវត្តិនីតិវិធី និងអង្គហេតុ

២. នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះ បានប្រកាសជាសាធារណៈអំពី សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ។ សាលដីកាជាលាយលក្ខណ៍អក្សរត្រូវបានផ្សព្វផ្សាយ និងដាក់ជូន កាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៨[1] ។

៣. សាលដីការបស់អង្គបុរេជំនុំជម្រះ បានកែប្រែលើដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង ឌុច ហេតុដូច្នេះហើយ ក៏បានធ្វើឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងសំណុំរឿងលេខ ០០១ ចូលជាស្ថាពរ ។ អនុលោមតាម វិធាន ៨០.១ នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក សហព្រះរាជអាជ្ញា មានរយៈពេល១៥ ថ្ងៃ ចាប់តាំងពីកាលបរិច្ឆេទនោះមក ដើម្បីដាក់ជូនក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង នូវបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ។

៤. នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឱ្យសហព្រះរាជអាជ្ញា ដាក់ជូនក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង នៅពេលព្រមជាមួយគ្នានឹងការដាក់អនុលោម

---

[1] *ករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច”,* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច”, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២), ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០០៨, D99/3/42, ERN 249846-249887 ។

តាមវិធាន៨០.១ នៃវិធានផ្ទៃក្នុង នូវ "បញ្ជីនៃកញ្ចប់វត្ថុតាងមួយ គឺមានន័យថា វត្ថុដែលមានលក្ខណៈរូបីទាំងឡាយណាដែលសហព្រះរាជអាជ្ញាមានបំណងចង់ប្រគល់ឱ្យសម្រាប់រឿងក្ដីនេះ" និង"បញ្ជីឯកសារថ្មីៗមួយ ដែលសហព្រះរាជអាជ្ញាមានបំណងប្រគល់ឱ្យសម្រាប់រឿងក្ដីនេះ"[2] ។

៥. ដូចអ្វីដែលអង្គជំនុំជម្រះសាលាដំបូងនេះបានបង្គាប់ កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ សហព្រះរាជអាជ្ញា បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដាក់ឯកសារបន្ថែមនៅក្នុងករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ព្រមជាមួយនឹងឧបសម្ព័ន្ធ ក ខ និង គ[3] ដែលជាការសម្ងាត់ ។ សហព្រះរាជអាជ្ញាបានជូនយោបល់ដល់អង្គជំនុំជម្រះសាលាដំបូងថា សហព្រះរាជអាជ្ញា មិនមានបំណងផ្ដល់នូវ "វត្ថុដែលមានលក្ខណៈជារូបីណាមួយ" ធ្វើជាកញ្ចប់ភស្តុតាងនោះទេ ដោយសារតែសហព្រះរាជអាជ្ញាបានយល់អំពីលក្ខខណ្ឌ ប៉ុន្តែមានបំណងចង់ផ្ដល់តែ "ភស្តុតាងឯកសារដែលបានស្កេន(scanned) រួចហើយដែលបច្ចុប្បន្នកំពុងមានស្រាប់នៅក្នុងសំណុំរឿង ដែលនៅក្នុងនោះរួមមានឯកសារជាទម្រង់រូបថត និង វីឌីអូ"[4] តែប៉ុណ្ណោះ។ បញ្ជីឈ្មោះមួយនៃឯកសារថ្មីៗ ដែលសហព្រះរាជអាជ្ញាមានបំណងផ្ដល់ជូន គឺបានដាក់ជូនជា **ឧបសម្ព័ន្ធ គ**[5] ។ សហព្រះរាជអាជ្ញា ក៏បានទទួលបន្ទុកយ៉ាងច្បាស់លាស់ផងដែរ ក្នុងការ "ដាក់បង្ហាញជូន

---

[2] *ករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច"*, សេចក្ដីជូនដំណឹងពីកិច្ចប្រជុំរៀបចំសវនាការ និងដីកាបង្គាប់ឱ្យភាគីដាក់ឯកសារបន្ថែម, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ ២០០៨, E5, ERN 250117-250121, កថាខណ្ឌទី៤(ខ) និងកថាខណ្ឌទី៤(គ) ។

[3] *ករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច"*, ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យដាក់ឯកសារបន្ថែម នៅក្នុងករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" រួមជាមួយនឹងឧបសម្ព័ន្ធ **ក ខ** និង **គ** ដែលជាការសម្ងាត់, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០៨, E5/2, ERN 268747-268775 [*ចាប់ពីនេះតទៅហៅថា* ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង] ។

[4] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌទី១៨ ។

[5] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌទី១០ និង**ឧបសម្ព័ន្ធ គ** (ERN 268771-268775) ។

អង្គជំនុំជម្រះសាលាដំបូង នូវភស្តុតាងណាមួយផ្សេងទៀតដែលខ្លួនបានដឹង មិនថាភស្តុតាងនោះជាភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកនោះទេ”[6] ។

៦. កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨ គឺមួយសប្តាហ៍បន្ទាប់ពីការដាក់ជូនរបស់សហព្រះរាជអាជ្ញានោះ មជ្ឈមណ្ឌលឯកសារកម្ពុជា(DC-Cam) បានប្រកាសជូនដំណឹងដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអន្តរជាតិនានាថា ខ្លួនបានទទួលនូវកម្រងខ្សែភាពយន្តមួយចំនួន ពីរដ្ឋាភិបាលវៀតណាម ។ នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩ ភ្លាមៗបន្ទាប់ពីការវិលត្រឡប់របស់ខ្លួនពី ការឈប់សម្រាកបុណ្យណូអែល/ចូលឆ្នាំសកលមកវិញទើបលោក គ្រេក អិតឈីសិន (Craig Etcheson) ដែលជាអ្នកស៊ើបអង្កេតនៃការិយាល័យសហព្រះរាជអាជ្ញាត្រូវបានចាត់តាំងឲ្យទៅពិនិត្យមើលខ្សែភាពយន្តទាំងអស់នោះឡើងវិញ ដើម្បីកំណត់ថា តើវាមានតម្លៃជាភស្តុតាងនីយភាព ចំពោះករណីរឿងដែលកំពុងរង់ចាំនៅចំពោះមុខតុលាការនេះដែរឬទេ ។

៧. កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៩ លោក អិតឈីសិន ដែលជាអ្នកស៊ើបអង្កេត និងលោក តាន់ សេណារ៉ុង ដែលជាអ្នកជំនួយការជាន់ខ្ពស់របស់សហព្រះរាជអាជ្ញា បានទៅធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដើម្បីពិនិត្យមើលនូវកម្រងខ្សែភាពយន្តនោះរបស់វៀតណាម ហើយបានកំណត់ថាខ្សែភាពយន្តទាំងនោះទំនងជាមានតម្លៃជាភស្តុតាងនីយហេតុសម្រាប់សំណុំរឿងទាំងពីរ ទាំងលេខ ០០១ និង ០០២ ។ ដោយហេតុនេះ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០០៩ ក.ស.ព បានបញ្ជូនសំណើជាផ្លូវការមួយទៅ DC-Cam ដើម្បីសុំឲ្យផ្តល់នូវច្បាប់ចម្លងនៃខ្សែភាពយន្តទាំងនោះ ។ DC-Cam បានផ្តល់ជូននូវច្បាប់ចម្លងទាំងនោះមកឲ្យ ក.ស.ព ហើយកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៩ វេលាម៉ោង ៦:០០ ល្ងាច ។

៨. ចាប់តាំងពីបានទទួលភស្តុតាងនេះពី DC-Cam មក អ្នកស៊ើបអង្កេត ក.ស.ព បានធ្វើការពិនិត្យមើលដោយយកចិត្តទុកដាក់នូវកម្រងខ្សែភាពយន្តនេះទាំងមូល ហើយបានកំណត់ថាមានកំណាត់ខ្សែភាពយន្តចំនួនពីរខ្សែដែលជាប់ទាក់ទងទៅនឹងសំណុំរឿងលេខ ០០១ ។

[6] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌទី១៧ ។

នៅក្នុងកំណាត់ខ្សែភាពយន្តទាំងនោះមានរូបភាពនានាអំពីមន្ទីរស-២១ ដែលត្រូវបានគេថតនៅក្នុងពេលភ្លាមៗបន្ទាប់ពីការរុករកឃើញមន្ទីរនេះដោយកងកម្លាំងវៀតណាម ដែលក្នុងនោះរួមមានឈុតស្តីពីបន្ទប់ឃុំឃាំងនៅក្នុងគុក, ឧបករណ៍ផ្សេងៗសម្រាប់ធ្វើការបង្ខាំងអ្នកទោស និងសាកសពជាច្រើន ។ កំណាត់នៃខ្សែភាពយន្តទាំងពីរកំណាត់នេះ (ERNs V00271181-V00271181 និង V00271182-V00271182) ត្រូវបានចម្លងទៅជា ឌីវីឌី(DVD) ដែលត្រូវបានភ្ជាប់មកជា **ឧបសម្ពន្ធ ក** នៅក្នុងញត្តិនេះ។

## ៣. សេចក្តីសំអាង

### ក. វិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក អនុញ្ញាតឱ្យសហព្រះរាជអាជ្ញា បង្ហាញជូននូវភស្តុតាងថ្មីៗ និង ដាក់បញ្ចូលបន្ថែមនូវបញ្ជីនៃឯកសារថ្មីៗរបស់ខ្លួន

៩. វិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក មានបញ្ញត្តិដែលអនុញ្ញាតឱ្យសហព្រះរាជអាជ្ញា ធ្វើការកែប្រែ ឬដាក់បន្ថែមនូវបញ្ជីឯកសារថ្មីៗរបស់ខ្លួន ដែលបានដាក់ជូនកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ និង ដាក់បញ្ចូលនូវខ្សែភាពយន្តដែលទើបតែរកឃើញថ្មីៗដែលបានមកពីDC-Cam ដើម្បីធ្វើជាភស្តុតាង នៅពេលសវនាការ ។

១០. ទីមួយ វិធាន ៣៩.៤ នៃវិធានផ្ទៃក្នុងបានចែងថា តាមរយៈពាក្យបណ្តឹងរបស់ភាគីពាក់ព័ន្ធ អង្គជំនុំជម្រះ (ដែលក្នុងនោះរាប់បញ្ចូលទាំង អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.កផង) អាច៖ “ ក. ពន្យារពេលវេលាកំណត់ដែលខ្លួនបានសម្រេច ខ. ទទួលស្គាល់ថាមានសុពលភាពចំពោះកិច្ចទាំងឡាយណា ដែលបានអនុវត្តក្រោយពេលវេលាកំណត់ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល” ។ ដូច្នេះ វិធាន ៣៩.៤ នឹងអនុញ្ញាតឱ្យ អង្គជំនុំជម្រះសាលាដំបូង ពន្យារពេលវេលាសម្រាប់ការដាក់បញ្ជីឯកសារ និងកញ្ចប់វត្ថុតាងថ្មីៗរបស់សហព្រះរាជអាជ្ញា ឬមួយក៏ទទួលស្គាល់ និងទទួលយកនូវបញ្ជីដែលបានដាក់បន្ថែម ឬដែលបានកែប្រែ ។ ដោយសារថា ភស្តុតាងពាក់ព័ន្ធនេះមិនត្រូវបានគេរកឃើញពីមុនមកទេ

00275170

E5/10



រហូតទាល់តែមកដល់កាលបរិច្ឆេទដំបូងដែលកំណត់ត្រូវដាក់បញ្ជីឯកសារ និងកញ្ចប់វត្ថុតាងថ្មីៗទើបបានរកឃើញនោះ វាជាកិច្ចមួយដ៏ត្រឹមត្រូវដែលអង្គជំនុំជម្រះសាលាដំបូង ត្រូវចាត់ការតាមបែបនេះ និងអនុញ្ញាត ឲ្យមានការដាក់ជូននូវបញ្ជីបន្ថែម ។

១១. ទី២ វិធាន៩២ នៃវិធានផ្ទៃក្នុងបានអនុញ្ញាតឱ្យភាគីនានា "រហូតទល់នឹងពេលបិទកិច្ចពិភាក្សាដេញដោល"អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ហើយក៏អាចដាក់ជូនអង្គជំនុំជម្រះនូវភស្តុតាងទាំងឡាយណាដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស្វែងរកការពិត"។ ដូចដែលបានពិភាក្សាខាងលើរួចមកហើយខ្សែភាពយន្តដែលទើបតែបានទទួលមកថ្មីនេះមានកំណាត់មួយចំនួនដែលបរិយាយអំពីមន្ទីរស-២១ ដែលស្ថិតក្នុងពេលភ្លាមៗបន្ទាប់ពីត្រូវបានរកឃើញដោយកងទ័ពវៀតណាមដែលមានការជាប់ទាក់ទងគ្នាយ៉ាងខ្លាំងដែលមានប្រយោជន៍ដល់ការស្វែងរកការពិតអំពីមន្ទីរសន្តិសុខស-២១។

### ខ. ក្នុងកម្រងខ្សែភាពយន្តដែលផ្តល់ឲ្យដោយរដ្ឋាភិបាលវៀតណាម ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា មានភស្តុតាងដែលមានការជាប់ទាក់ទងដល់ដំណើរការនីតិវិធីទាំងនេះ

១២. ខ្សែភាពយន្តដែលរដ្ឋាភិបាលវៀតណាមបានផ្តល់ឲ្យទៅ DC-Cam ហើយដែល ក.ស.ព បានពិនិត្យមើលឡើងវិញក្នុងពេលថ្មីៗនេះ មានកំណាត់ខ្សែភាពយន្តចំនួនពីរខ្សែដែលទាក់ទងទៅនឹងបទចោទនានាប្រឆាំងនឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច ហើយដែលនឹងត្រូវអង្គជំនុំជម្រះនេះធ្វើការជំនុំជម្រះក្តីរូបគាត់លើបទចោទទាំងនេះ ។

១៣. កំណាត់ទី១ដែលមានការជាប់ទាក់ទង គឺនៅរយៈពេលបញ្ចាំងដល់ត្រង់នាទីទី៧ និងវិនាទីទី៣៥ និងដែលចលនានៃរូបភាពមានពណ៌ខ្មៅ-ស គ្មានសម្លេង ដែលបង្ហាញឡើងដើម្បីពិពណ៌នាអំពីបរិវេណពហុទីតាំងផ្នែកកណ្តាលនៃមន្ទីរស-២១ នៅក្នុងពេលភ្លាមៗបន្ទាប់ពីការរកឃើញមន្ទីរនេះ ដោយកងទ័ពវៀតណាម នៅថ្ងៃ ឬមុំថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ ។ រូបភាពទាំងនោះរួមមានឈុតឆាកផ្សេងៗ ស្តីពីខ្លោងទ្វារចូលធំរបស់បរិវេណពហុទីតាំងផ្នែកកណ្តាលនៃមន្ទីរស-២១ ឈុតដែលបង្ហាញឱ្យឃើញពីទិដ្ឋភាពរួមនៅផ្នែកខាងក្នុងនៃបរិវេណ

00275171

E5/10



ពហុទីតាំង និងឈុតឲ្យឃើញអំពីប្រភេទផ្សេងៗនៃបន្ទប់ឃុំឃាំង ហើយនិងគ្រឿងឧបករណ៍ផ្សេងៗសម្រាប់បង្ខាំងអ្នកទោស នៅក្នុងបរិវេណនៃពហុទីតាំងផ្នែកកណ្តាលនៃមន្ទីរស-២១ ព្រមទាំងសាកសពកំបុតក្បាលដែលនៅជាប់ច្រវាក់ភ្ជាប់ទៅនឹងគ្រែនៅក្នុងអាគារ ក នៃបរិវេណទីតាំង ក្នុងចំណោមអ្វីៗដទៃទៀតជាច្រើន ។

១៤. កំណាត់ទី២ដែលមានការជាប់ទាក់ទង គឺនៅរយៈពេលបញ្ចាំងដល់ត្រង់នាទីទី៤ និងដែលចលនានៃរូបភាពដែលមានពណ៌ខ្មៅ-ស គ្មានសម្លេង ដែលបង្ហាញឡើងដើម្បីពិពណ៌នាអំពីកងទ័ពវៀតណាមកំពុងតែយកទារកដែលនៅរស់រានមានជីវិតពីរនាក់ និងកូនក្មេងពីរនាក់ចេញពីបរិវេណពហុទីតាំងផ្នែកកណ្តាលនៃមន្ទីរស-២១ ក្នុងពេលភ្លាមៗបន្ទាប់ពីការរកឃើញមន្ទីរនេះដោយកងទ័ពវៀតណាមដែរ ។ ឈុតទាំងនេះ គឺមានការជាប់ទាក់ទង ពីព្រោះ ៖ (ក) វាបានបញ្ជាក់ការពិតដែលស៊ីសង្វាក់គ្នាទៅនឹងការផ្តល់សក្ខីកម្មរបស់សាក្សីនានាដែលថា កូនៗរបស់កម្មាភិបាលដែលត្រូវគេចាប់ខ្លួនក៏ត្រូវបានគេយកទៅដាក់នៅក្នុងមន្ទីរស-២១ដែរ ។ និង (ខ) ទារកដែលឃើញនៅក្នុងខ្សែភាពយន្តនេះឃើញហាក់ដូចជាមានសុខភាពទន់ខ្សោយខ្លាំងណាស់ ដែលជាការគាំទ្រចំពោះការចោទប្រកាន់ដែលថា លក្ខខណ្ឌនៅក្នុងមន្ទីរស-២១ គឺលក្ខណៈអមនុស្សធម៌ ។

១៥. នេះគឺជាឈុតនៃខ្សែភាពយន្តតែមួយគត់ដែលត្រូវបានទទួលស្គាល់ថា បានថតស្តីពីទួលស្លែងនៅក្នុងពេលបន្ទាប់ៗគ្នានឹងអម្លុងពេលដែលទីកន្លែងនេះត្រូវបានគេប្រើប្រាស់ធ្វើជាពន្ធនាគារមួយរបស់កម្ពុជាប្រជាធិបតេយ្យ ។

## គ. សហព្រះរាជអាជ្ញាបានធ្វើសកម្មភាពប្រកបដោយការយកចិត្តទុកដាក់ម៉ត់ចត់នៅក្នុងការពិនិត្យឡើងវិញទៅលើភស្តុតាងថ្មីៗដែលបានរកឃើញ និងក្នុងការដាក់បង្ហាញភស្តុតាងនេះជូនទៅអង្គជំនុំជម្រះសាលាដំបូង

១៦. ភស្តុតាងដែលលើកឡើងនេះ សហព្រះរាជអាជ្ញាមិនបានដឹងទេ រហូតទាល់តែមកដល់ក្រោយកាលបរិច្ឆេទដែលកំណត់ត្រូវឲ្យសហព្រះរាជអាជ្ញាដាក់នូវបញ្ជីឯកសារ និងកញ្ចប់វត្ថុតាងថ្មី

ទើបដឹង ដោយសារការជូនដំណឹងអំពីការដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបាននូវកម្រងខ្សែភាពយន្តថ្មីពីរដ្ឋាភិបាលវៀតណាមនេះ គឺបានធ្វើឡើងនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨ ។ សហព្រះរាជអាជ្ញា មិនបានដឹងអំពី ឬមិនមានមូលដ្ឋានស្តីពីការបានទទួលនូវហ្វីលខ្សែភាពយន្តទាំងនេះ តាំងពីមុនពេលនេះនោះទេ ។

១៧. បន្ទាប់ពីបានទទួលដំណឹងថា មានហ្វីលខ្សែភាពយន្តទាំងនេះ សហព្រះរាជអាជ្ញា ក៏បានធ្វើសកម្មភាពដោយមានការយកចិត្តទុកដាក់យ៉ាងម៉ត់ចត់ ដើម្បីឱ្យបានទទួលមកនូវសេចក្តីចម្លងនៃហ្វីលខ្សែភាពយន្តទាំងនេះ ធ្វើការពិនិត្យមើលខ្សែភាពយន្តទាំងនេះឡើងវិញដើម្បីរកភស្តុតាងភវនីយភាព និងដើម្បីបង្ហាញជូនដល់អង្គជំនុំជម្រះសាលាដំបូង ។ អត្ថិភាពនៃភស្តុតាងនេះត្រូវបានប្រកាសជូនដំណឹងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងពេលឈប់សម្រាកបុណ្យណូអែល ។ នៅក្នុងសប្តាហ៍ទី១ បន្ទាប់ពីថ្ងៃឈប់សម្រាកបុណ្យទើប សហព្រះរាជអាជ្ញា អាចទទួលបាននូវហ្វីលខ្សែភាពយន្តទាំងនេះ ហើយក៏បានចាប់ផ្តើមធ្វើការពិនិត្យមើលនូវខ្សែភាពយន្តទាំងនេះឡើងវិញដើម្បីរកមើលព័ត៌មានដែលជាប់ទាក់ទង ។ សហព្រះរាជអាជ្ញា បានបញ្ចប់ការពិនិត្យមើលឡើងវិញនេះនៅមុនកិច្ចប្រជុំរៀបចំសវនាការដែលអង្គជំនុំជម្រះនេះបានបើកធ្វើកាលពីថ្ងៃទី១៥ និង១៦ ខែមករា ឆ្នាំ២០០៩ ដែលបានផ្តល់លទ្ធភាពឱ្យសហព្រះរាជអាជ្ញា អាចធ្វើការប្រកាសជូនដំណឹងស្តីពីចេតនារបស់ខ្លួនដែលចង់បង្ហាញជូននូវឯកសារផ្សេងៗដល់អង្គជំនុំជម្រះនានាព្រមទាំងដល់ភាគីដទៃៗទៀត នៅក្នុងអម្លុងពេលនៃកិច្ចប្រជុំនោះ។

## ៤. សេចក្តីសន្និដ្ឋាន

១៨. ដោយមូលហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញា សូមស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតឱ្យយើងខ្ញុំបានដាក់នូវខ្សែភាពយន្តដែលទើបរកឃើញថ្មីដែលមានឈុត

00275173

E5/10

*សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ*

ស្តីពីមន្ទីរស-២១ ហើយសូមឲ្យអង្គជំនុំជម្រះសាលាដំបូង ទទួលយល់ព្រមយកធ្វើជាភស្តុតាង នៅក្នុងពេលសវនាការលើករណីរឿងក្តីនេះ ៕

ធ្វើនៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩

**សហព្រះរាជអាជ្ញា**

| | |
|---|---|
| **លោកយ៉េត ចរិយា** | **លោក** William SMITH |
| សហព្រះរាជអាជ្ញារង | សហព្រះរាជអាជ្ញារង |